# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# សកម្មភាព និងបទពិសោធន៍នៃការឆ្លើយតប មេរោគអេដស៍ និងជំងឺអេដស៍របស់ គណៈកម្មការប្រយុទ្ធនឹងអេដស៍ ឃុំព្រែកអំបិល

ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០១៩

# មាតិកា

- ស្ថានភាពភូមិសាស្ត្រឃុំ
- អង្គការដៃគូដែលមាននៅក្នុងឃុំ
- យន្តការឆ្លើយតប  នឹងការបង្ការការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍
- លទ្ធផលនៃការឆ្លើយតបនិងការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍
- យន្តការនៃការប្រើប្រាស់ថវិកាឃុំក្នុងការគាំទ្រដល់អ្នកជំងឺអេដស៍
- ទិសដៅ និងសំណូមពរ

# ស្ថានភាពភូមិសាស្ត្រ

- ឃុំព្រែកអំបិលះមានទីតាំងខាងត្បូង សាលាស្រុកស្អាង ចំងាយប្រហែល ១៥ គ.ម. មានស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ចែកជាពីរផ្នែក គឺ មួយផ្នែក ស្ថិតនៅតាមបណ្តោយ ផ្លូវជាតិលេខ ២១ មាន៨ភូមិ និង មួយផ្នែកទៀត គឺ រស់នៅស្របតាមមាត់ស្ទឹងព្រែកអំបិល មាន៨ភូមិដែរ។
- មានព្រំប្រទល់៖

ខាងជើងជាប់ ឃុំកោះខែល ខាងត្បូងជាប់ : ឃុំកោះធំខ ស្រុក កោះធំ

ខាងលិចជាប់ ឃុំក្រាំងយ៉ូវ និងឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ និង

ខាងកើតជាប់ ទន្លេបាសាក់ ឃុំខ្ពប

- ចំនួនភូមិ ៖ មានភូមិចំនួន ១៦
- ចំនួនមណ្ឌលសុខភាព ៖ ចំនួន ២កន្លែង
- វត្តចំនួន ៤, វិទ្យាល័យ ១កន្លែង, អនុវិទ្យាល័យ ២ និងសាលាបឋមសិក្សាចំនួន ៧កន្លែង
- ចំនួនគ្រួសារសរុប: ៥ ២៧២គ្រួសារ ប្រជាជនសរុប ២៣ ៥៩៨ នាក់
  - ❖ ប្រុស ៖ ១១ ៩២៤នាក់ កុមារ ១ ១៩២នាក់
  - ❖ ស្រី ៖ ១១ ៦៧៤នាក់ កុមារ ១ ៣៥២នាក់
  - ❖ អ្នកជំងឺអេដស៍សរុប ៖ ៥១នាក់ ប្រុស ៖ ១៥នាក់ ស្រី ៖ ៣៦នាក់
  - ❖ កុមាររស់នៅជាមួយមេរោគអេដស៍ ៖ ៥ ប្រុស៣ នាក់ ស្រី ៖ ២នាក់

# អង្គការពាក់ព័ន្ធក្នុងតំបន់

| ឈ្មោះអង្គការ | គម្រោង | សកម្មភាពគម្រោង | |
|---|---|---|---|
| | | ឆ្នាំបញ្ចប់ | កំពុងដំណើរការ |
| IDE | ធ្វើបង្គន់អនាម័យ | ២០១៦ | |
| អង្គការលំនៅឋានមនុស្សជាតិ | សាងសង់ផ្ទះ | | កំពុងដំណើរការ |
| **អង្គការអប់រំ និងថែទាំជំងឺអេដស៍ (ឆេក)** | **ការធ្វើឱ្យប្រសើរនូវការគាំទ្រដល់អ្នករស់នៅជាមួយជំងឺអេដស៍** | **មិថុនា ២០១៩** | |

# យន្តការឆ្លើយតបនិងការបង្ការ ការរីករាលដាលនៃជំងឺអេដស៍

- *ការផ្សព្វផ្សាយអប់រំ ជាបន្តបន្ទាប់*
- *ការរៀបចំអ្នកស្ម័គ្រចិត្ត នៅតាមសហគមន៍*
- *ពង្រឹងសមត្ថភាពដល់ក្រុមអ្នកស្ម័គ្រចិត្ត*
- *មានការគាំទ្រពីអង្គការដៃគូ  និងអាជ្ញាធរពាក់ព័ន្ធ*

# លទ្ធផលនៃការឆ្លើយតប និងការរីករាលដាលនៃជំងឺអេដស៍

## កិច្ចសហប្រតិបត្តិការជាមួយអង្គការផ្សេងៗ

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីមេរោគអេដស៍ និងជំងឺអេដស៍
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកសាងផែនការក្នុងការបញ្ចូលកម្មវិធីអេដស៍ក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់
- ចូលរួមផ្សព្វផ្សាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍តាមសហគមន៍
- ការឧបត្ថម្ភសម្ភារ និងថវិកាដល់អ្នកជំងឺអេដស៍
- **ចុះសួរសុខទុកដល់អ្នកជំងឺអេដស៍ តាមរយៈគណៈកម្មការឃុំ (មេឃុំ កិច្ចការនារីឃុំ មេភូមិ)**







សកម្មភាពមេឃុំ កិច្ចការនារីឃុំ និង
ស្មៀនឃុំចូលរួមក្នុងវគ្គបណ្តុះបណ្តាល
ស្តីពីការកសាងផែនការឃុំឆ្លើយតប
មេរោគអេដស៍ និងជំងឺអេដស៍



ឃុំដែលជាប់ជាឃុំគំរូក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍

# ការបញ្ជ្រាបកម្មវិធីអេដស៍ក្នុងផែនការឃុំ/សង្កាត់

- បានបញ្ចូលកម្មវិធីអេដស៍ក្នុងផែនការការឃុំសង្កាត់ ៖ ក្នុងឆ្នាំ២០១៩
- សកម្មភាព៖
  - **អប់រំសុខភាព តាមសហគមន៍ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍**
  - ឧបត្ថម្ភ ថវិកា ដល់អ្នកជំងឺអេដស៍សម្រាប់សាហ៊ុយធ្វើដំណើរបើកថ្នាំនៅមន្ទីរពេទ្យ **(មួយឆ្នាំ ៤ម៉ឺនរៀល ក្នុងមួយនាក់)**
  - **លើកកម្ពស់ជីវភាពរស់នៅសម្រាប់អ្នកជំងឺអេដស៍ក្រីក្រ** (បង្កើតមុខរបរខ្នាតតូចដល់អ្នកជំងឺ/ឬអ្នកផ្ទុកមេរោគ (ចិញ្ចឹមមាន់ ទា លក់ដូរកាត់ដេរ)
  - **សាងសង់លំនៅដ្ឋានសម្រាប់អ្នកជំងឺអេដស៍ (អង្គការលំនៅឋាន)**

ប្រភពថវិកាឆ្លើយតបមេរោគអេដស៍ ៖

- **ថវិកាឃុំ ៖ ចំនួន  ៣ ៥៤០ ០០០រៀល**
- សប្បុរសជម៌ ៖    ១ ៥០០ ០០០រៀល
- អង្គការដៃគូ ៖

# សកម្មភាពគាំទ្រលើកបញ្ហាអេដស៍
# ឃុំព្រៃកអំបិលឆ្នាំ២០១៩

- សាហ៊ុយទៅបើកថ្នាំនៅតាមមន្ទីរពេទ្យ ក្នុងម្នាក់៤០ ០០០៛ ក្នុង១ឆ្នាំ (អ្នកជំងឺ៥១នាក់ ក្នុងម្នាក់៤០ ០០០៛ ផ្តល់តាមរយៈ គ ក ន ក ឃុំ)។
- បានចុះសួរសុខទុក្ខ តាមខ្នងផ្ទះដល់អ្នកជំងឺអេដស៍១ត្រីមាសម្តង តាមរយៈ គ.ក.ន.ក (ការពិនិត្យមើលការប្រើប្រាស់ថ្នាំ, អប់រំអំពីអនាម័យ ( ក្នុងនោះក៏មានការចែកនូវកញ្ចប់ សាប៊ូ ជូនដល់អ្នកជំងឺ)។
- ការប្រជុំផ្សព្វផ្សាយអប់រំអនាម័យ តាមសហគមន៍ ១ឆ្នាំ ២លើក(មានអាហារសម្រន់)។
- ក្រៅពីនេះក៏នៅមានការគាំទ្រមន្ទីរកិច្ចនារីស្រុក ខេត្ត ក៏ដូចជាគណៈពង្រឹងឃុំ សម្រាប់ឧបត្ថម្ភ ដល់អ្នកជំងឺអេដស៍ផងដែរ។

# យន្តការនៃការប្រើប្រាស់ថវិកាឃុំក្នុងការគាំទ្រដល់អ្នកជំងឺអេដស៍

- ការធ្វើផែនការ និងដាក់បញ្ចូលសកម្មភាព អេដស៍ ក្នុងកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំនីមួយៗ។
- ការធ្វើផែនការថវិកាប្រចាំឆ្នាំរបស់ឃុំ **ក្នុងនោះមានថវិកាសម្រាប់ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍**
- ការទូទាត់ចំណាយនៃ**ការឆ្លើយតបមេរោគអេដស៍**

**(ជំពូក៦០ ៦១,៦២)**

# បញ្ហាប្រឈមនឹងការឆ្លើយតបនៃការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍

- ថវិកាឃុំមានកំណត់សម្រាប់សេវាកម្មសង្គម
- ថវិកាឆ្លើយតបនឹងមេរោគអេដស៍តិចតួច
- ចំណេះដឹងអ្នកពាក់ពន្ធ័ក្នុងការកសាងផែនការឆ្លើយតបនឹងមេរោគអេដស៍នៅមានកម្រិត
- ការប្រើប្រាស់ថ្នាំញៀន
- ការសេពគ្រឿងស្រវឹង

# ទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២០

- បន្តយន្តការគាំទ្រ លើកគម្រោងសេវាសង្គម ក្នុងនោះមានកម្មវិធីអេដស៍ ដែលមានថវិកាសរុប ៖ ៥ ០០០ ០០០៛ (ថវិកាឃុំ)
- បង្កើនការចុះសួរសុខទុកតាមផ្ទះអ្នកជំងឺអេដស៍
- ស្វែងរកមូលនិធិផ្សេងៗក្នុងការគាំទ្រដល់អ្នកជំងឺអេដស៍តាមរយៈហិបមនុស្សធម៌
- បង្កើនការចុះអប់រំផ្សព្វផ្សាយទាក់ទងនឹងជំងឺអេដស៍ មេរោគអេដស៍

# សំណូមពរ

- *បង្កើនកញ្ចប់ថវិកាឃុំក្នុងការឆ្លើយតបមេរោគអេដស៍ឃុំ*
- ***សូមឱ្យមានការចូលរួមពី អង្គការ មន្ទីរ ពាក់ព័ន្ធ និងសប្បុរសជនក្នុងការគាំទ្រដល់អ្នកជំងឺអេដស៍***
- *ក្រសួងសុខាភិបាល មានកម្មវិធីថែទាំ អ្នកជំងឺអេដស៍ នៅតាមមណ្ឌលសុខភាព* (*ការបើកថ្នាំ .....ជាដើម*)

# សូមអរគុណ
# ចំពោះការយកចិត្តទុកដាក់ស្តាប់